ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាធម្មនុញ្ញ**

## មតិផ្ដើមរបស់ឯកឧត្តមប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ថ្លែងក្នុងពិធីផ្សព្វផ្សាយអំពីខ្លឹមសាររដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ និងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ នៅសាលាភូមិន្ទរដ្ឋបាល ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៣

សូមគោរពគណៈអធិបតី

សម្ដេច អ្នកអង្គម្ចាស់ ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា សាស្ត្រាចារ្យ មន្ត្រីរាជការ និង និស្សិត ទាំងអស់ជាទីរាប់អាន

ជាបឋម តាងនាមគណៈប្រតិភូក្រុមប្រឹក្សាធម្មនុញ្ញ និង ក្នុងនាមខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណចំពោះគណៈគ្រប់គ្រងនៃសាលាភូមិន្ទរដ្ឋបាល ដែលបានធ្វើលិខិតអញ្ជើញលេខ ០៦ ស.ភ.រ ចុះថ្ងៃទី ០៩ ខែមករា ឆ្នាំ ២០១៣ ឱ្យក្រុមប្រឹក្សាធម្មនុញ្ញមកធ្វើបាឋកថាផ្សព្វផ្សាយខ្លឹមសាររដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ និង សមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញនារសៀលថ្ងៃនេះ ហើយក៏សូមស្វាគមន៍យ៉ាងកក់ក្ដៅចំពោះវត្តមានឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញាទាំងអស់ ដែលបានបញ្ចូលក្នុងកាលវិភាគសិក្សានៃសាលាភូមិន្ទរដ្ឋបាល ញ៉ាំងឲ្យមានពិធីផ្សព្វផ្សាយនៅពេលនេះ ។

មុននឹងចូលដល់ប្រធានបទ ខ្ញុំសូមអនុញ្ញាតឧទ្ទេសនាមសមាសភាពគណៈ ប្រតិភូក្រុមប្រឹក្សា-ធម្មនុញ្ញ វត្តមានថ្ងៃនេះ មាន ...........................................................................

...........................................................................................................

សម្ដេច អ្នកអង្គម្ចាស់ ឯ កឧត្តម លោកជំទា វ លោក លោកស្រី អ្នកនាងកញ្ញា ទាំងអស់ជាទីគោរព នេះជាលើកទី៦ហើយដែលគណៈប្រតិភូក្រុមប្រឹក្សាធម្មនុញ្ញបានមកធ្វើបាឋកថាផ្សព្វផ្សាយនៅសាលាភូមិន្ទរដ្ឋបាលនេះ ដែលជាមូលដ្ឋានបណ្ដុះបណ្ដាល និងវិក្រឹត្យការមន្ត្រីរដ្ឋបាលសាធារណៈមធ្យម និង ជាន់ខ្ពស់របស់ព្រះរាជាណាចក្រកម្ពុជា ។

ជាបន្ត ខ្ញុំមានកិត្តិយសជម្រាបពីប្រវត្តិរដ្ឋធម្មនុញ្ញរបស់ប្រទេសយើងដូចតទៅ ប្រទេសកម្ពុជាចាប់ផ្ដើមមានរដ្ឋធម្មនុញ្ញតាំងពីឆ្នាំ១៩៤៧ មកម្ល៉េះ ហើយបានផ្លាស់ប្ដូរជាបន្តបន្ទាប់អស់ចំនួន០៦ លើកមកហើយទៅតាមការផ្លាស់ប្ដូររបបនយោបាយ ។ ប៉ុន្តែក្នុងរបៀបវារៈរសៀលនេះ យើងលើកយកតែរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ដែលជាច្បាប់កំពូលរបស់ព្រះរាជាណាចក្រកម្ពុជា

និងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ មកធ្វើជាប្រធានបទសម្រា ប់ពិចារណាស្វែងយល់ ដោយមាន លោកជំទាវ ចែម ទេយ្យរិទ្ធ សមាជិកាក្រុមប្រឹក្សាធម្មនុញ្ញ ជ្រើសតាំងដោយ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ជាអ្នកឧទ្ទេសនាម ។

ខ្ញុំមានកិត្តិយស ជម្រាបជូនអំពីស្ថាប័នក្រុមប្រឹក្សាធម្ម នុញ្ញនៃព្រះរាជាណាចក្រកម្ពុជាផងដែរ។ ក្រុមប្រឹក្សាធម្មនុញ្ញ គឺជាស្ថាប័នកំពូលមួយឯករាជ្យ និង អព្យាក្រឹត ដែលមានចែងក្នុង ជំពូកទី១២ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ និង ត្រូវបានបង្កើតឡើងដោយព្រះរាជក្រម លេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។ ក្រុមប្រឹក្សាធម្មនុញ្ញ ចាប់ផ្តើមបំពេញការងាររបស់ខ្លួនពីថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ១៩៩៨ នៅអគារ “ស” ក្នុងបរិវេណវិមានរដ្ឋចំការមន។

ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចធានាការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និង ច្បាប់ដែលរដ្ឋសភាបានអនុម័ត និង ព្រឹទ្ធសភាបានពិនិត្យចប់ សព្វគ្រប់ហើយ ព្រមទាំងមានសិទ្ធិ ពិនិត្យ និងសម្រេចអំពីករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ការបោះឆ្នោត ជ្រើសតាំងសមាជិកព្រឹទ្ធសភា។

ក្រុមប្រឹក្សាធម្មនុញ្ញ ថ្វាយមតិព្រះមហាក្សត្រចំពោះសេចក្តីស្នើទាំងឡាយដែលសុំធ្វើការសើរើ និង វិសោធនកម្មរដ្ឋធម្មនុញ្ញ ។ ការសើរើ និង វិសោធនកម្មរដ្ឋធម្មនុញ្ញ ត្រូវហាមឃាត់ក្នុងកាលៈទេសៈ ប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ឬ កាលបើ ប៉ះពាល់ដល់ប្រព័ន្ធប្រជាធិបតេយ្យសេរីពហុបក្ស របប រាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ ។ ប្រការដែលព្រះមហាក្សត្រទ្រង់គ្រងរាជសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់ អំណាច មិនអាចសុំកែប្រែបានជាដាច់ខាត ។

ខ្ញុំសូមគូសបញ្ជាក់ថា ច្បា ប់ និង សេចក្តីសម្រេចទាំងឡាយនៃស្ថាប័ននានារបស់រដ្ឋ ត្រូវស្រប នឹងរដ្ឋធម្មនុញ្ញជាដាច់ខាត ។ ការអនុម័តទាំងឡាយណារបស់រដ្ឋសភា ដែលផ្ទុយនឹងគោលការណ៍ រក្សាការពារឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ហើយដែលនាំឱ្យ ប៉ះពាល់ដល់ឯកភាពនយោបាយ ឬ ការគ្រប់គ្រងរដ្ឋបាលរបស់ប្រទេសជាតិ នឹងត្រូវចាត់ទុកជា អសារសូន្យ ។ ក្រុមប្រឹក្សាធម្មនុញ្ញ ជាអង្គការតែមួយគត់ដែលមានសមត្ថកិច្ចសម្រេចអំពីមោឃភាព នេះ។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ គឺជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើ យមាន អានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនិងត្រូវចុះផ្សាយក្នុងរាជកិច្ច ។

ការបង្កើតស្ថាប័ននេះឡើង គឺដើម្បីរួមចំណែកក្នុងការពង្រឹងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ការគោរពសិទ្ធិមនុស្ស ការកសាងនីតិរដ្ឋក្នុងព្រះរាជាណាចក្រនៃយើង ។

ខ្ញុំសង្ឃឹមថា ពិធីផ្សព្វផ្សាយក្នុងថ្ងៃនេះ អាចចាត់ទុកជា វគ្គរៀនសូត្រខ្លីមួយដែលអាចនាំឱ្យមានការយល់ដឹងមួយកម្រិតថែមទៀតអំពីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ និង អំពីសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដើ ម្បីរួមគ្នាគោរព និង ប្រតិបត្តិ តាមដូចបទប្បញ្ញត្តិនៃវាក្យខណ្ឌទី១ នៃមាត្រា៤៩ នៃរដ្ឋធម្មនុញ្ញ ចែងថា ៖ ប្រជាពលរដ្ឋខ្មែរគ្រប់រូប ត្រូវគោរពរដ្ឋធម្មនុញ្ញ និង គោរពច្បាប់ ។

ជាទីបញ្ចប់ ខ្ញុំសូមថ្វាយព្រះពរ និង ជូនពរដល់សម្តេច អ្នកអង្គម្ចាស់ ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា ទាំងអស់ដែលចូលរួម សូ មបានប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និង ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

បន្តទៅនេះ ខ្ញុំសូមអនុញ្ញាតដឹកនាំកម្មវិធី ដោយសូមអញ្ជើញ លោកជំទាវ **ចែម ទេយ្យរិទ្ធ** សមាជិកាក្រុមប្រឹក្សាធម្មនុញ្ញ ធ្វើបាឋកថា ។

**សូមអរព្រះគុណ និង អរគុណ**